# វិទ្យាស្ថានសភាកម្ពុជា
PARLIAMENTARY INSTITUTE OF CAMBODIA
STRENGTHENING PARLIAMENTARY CAPACITY

# ព្រឹត្តប័ត្រព័ត៌មានសង្ខេប

**សប្តាហ៍ដែលបញ្ចប់**
**ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ២០១៩**

ចំណុចសំខាន់ៗ អំពីព័ត៌មានសេដ្ឋកិច្ច និងការអភិវឌ្ឍសារពើពន្ធនៅក្នុងបណ្តាប្រទេសជាសមាជិកអាស៊ាន និងនៅប្រទេសផ្សេងៗទៀត នៅក្នុងសប្តាហ៍នេះ គឺៈ

- រដ្ឋមន្ត្រីក្រសួងទេសចរណ៍ប្តេជ្ញានឹងចាត់វិធានការលើក្រុមហ៊ុនទេសចរណ៍ដែលផ្តល់កញ្ចប់សេវាកម្មតម្លៃ "សូន្យដុល្លារ"
- អាស៊ានក្លាយជាដៃគូធំទី២របស់ ចិន
- ផលិតកម្មឧស្សាហកម្មសហរដ្ឋអាមេរិក រក្សាស្ថានភាពមិនផ្លាស់ប្តូរនៅក្នុងខែមិថុនា

*ព្រឹត្តប័ត្រសង្ខេបព័ត៌មាននេះគឺជាព្រឹត្តិប័ត្រប្រចាំសប្តាហ៍ដែលរៀបចំឡើងដើម្បីតាមដានព័ត៌មានអំពីការអភិវឌ្ឍសេដ្ឋកិច្ច និងសារពើពន្ធថ្មីៗនៅក្នុងប្រទេសកម្ពុជា និងដៃគូពាណិជ្ជកម្មនានា។ ឯកសារនេះត្រូវបានធ្វើឡើងដោយក្រុមការងារបណ្តុះបណ្តាលសមត្ថភាពការវិភាគសារពើពន្ធរបស់វិទ្យាស្ថានសភាកម្ពុជា ក្នុងគោលបំណងពង្រឹងជំនាញនៃការធ្វើឯកសារ និងការស្រាវជ្រាវរបស់ខ្លួន។ ការងារនេះត្រូវបានព្យាយាមធ្វើឡើងដើម្បីអោយការវិភាគ និងអត្ថន័យ ដែលបានផ្តល់នៅក្នុងឯកសារនេះមានគុណភាពខ្ពស់។ ទោះជាយ៉ាងណាក៏ដោយ សូមអ្នកអានចាត់ទុកឯកសារនេះជាផ្នែកមួយនៃលំហាត់អនុវត្តន៍នៅក្នុងកំឡុងពេលនៃការបណ្តុះបណ្តាល យើងមិនអាចធានាថាឯកសារនេះល្អឥតខ្ចោះនោះទេ។*

## ព័ត៌មាន និងទិន្នន័យអំពីប្រទេសកម្ពុជា

### រដ្ឋមន្ត្រីក្រសួងទេសចរណ៍ប្តេជ្ញាចាត់វិធានការលើក្រុមហ៊ុនទេសចរណ៍ដែលផ្តល់កញ្ចប់សេវាកម្មតម្លៃ "សូន្យដុល្លារ"

ឯកឧត្តមរដ្ឋមន្ត្រីក្រសួងទេសចរណ៍ ថោង ខុន បានប្តេជ្ញាថានឹងធ្វើការបង្ក្រាបទៅលើក្រុមហ៊ុនដែលផ្តល់កញ្ចប់ទេសចរណ៍ "សូន្យដុល្លារ" ។ ការថ្លែងការនេះបានធ្វើឡើងនៅក្នុងសិក្ខាសាលាក្រសួងទេសចរណ៍ នៅខេត្តសៀមរាបកាលពីសប្តាហ៍មុន។

កញ្ចប់ទេសចរណ៍ "សូន្យដុល្លារ" បានទាក់ទាញអ្នកទេសចរតាមរយៈការផ្តល់សេវាដឹកជញ្ជូនដោយមិនគិតថ្លៃ ប៉ុន្តែគឺគ្រាន់តែជូនភ្ញៀវទេសចរទៅកាន់ហាង និងភោជនីយដ្ឋានដែលមានតម្លៃថ្លៃៗ ដែលជាកន្លែងដែលក្រុមហ៊ុនអាចទទួលបានកម្រៃជើងសារពីហាងទាំងនោះ។ ទង្វើបែបនេះអាចធ្វើឱ្យភ្ញៀវទេសចរមានអារម្មណ៍ថាខ្លួនត្រូវគេឆបោក និងអាចធ្វើអោយពួកគេរារែកក្នុងការប្រាប់ទៅអ្នកផ្សេងអោយមកលេងនៅប្រទេសកម្ពុជា។

ប្រធានសមាគមភ្នាក់ងារទេសចរណ៍កម្ពុជា លោកស្រី ឆាយ ស៊ីវលីន ក៏បានឯកភាពជាមួយប្រសាសន៍ឯកឧត្តមរដ្ឋមន្ត្រី ហើយក៏បានរាយការណ៍ដែរថា ការអនុវត្តរបស់ក្រុមហ៊ុនទេសចរណ៍បែបនេះកំពុងថមថយហើយ បន្ទាប់ពីមានការព្រមានម្តងហើយម្តងទៀតពីសំណាក់ក្រសួង។

កន្លងមកនេះ ប្រទេសកម្ពុជាទទួលបានជោគជ័យក្នុងរដូវកាលទេសចរណ៍ ដោយទទួលបានភ្ញៀវទេសចរ ១,៨ លាននាក់នៅត្រីមាសទី១ ក្នុងឆ្នាំ២០១៩ នេះ គឺកើនឡើង ៩,៧% បើប្រៀបធៀបទៅនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។

## តារាងប្រចាំសប្តាហ៍៖ ការចំណាយផ្នែករដ្ឋបាល ដោយក្រសួង និងស្ថាប័នសាធារណៈ

តារាងសប្តាហ៍នេះបង្ហាញពីការចំណាយរដ្ឋបាលទូទៅរបស់ក្រសួង និងស្ថាប័នសាធារណៈទាំងអស់ ក្នុងរយៈពេលប្រាំខែដំបូងនៃឆ្នាំ២០១៩ ធៀបទៅនឹងឆ្នាំ២០១៨។ ការអនុវត្តចំណាយរដ្ឋបាលមានលក្ខណៈឡើងចុះលាយឡំគ្នាក្នុងកំឡុងពេលនេះ។ ការចំណាយដែលខ្ពស់បំផុតគឺនៅក្នុងខែមករា ដែលស្មើនឹង ៤២១ ប៊ីលានរៀល ឬក៏ខ្ពស់ជាង៣ ដងនៃការចំណាយនៅខែមករាកាលពីឆ្នាំ២០១៨ ។ ការចំណាយបានធ្លាក់ចុះយ៉ាងខ្លាំងនៅខែកុម្ភៈ មុនកើនឡើងវិញនៅខែមេសា និងឧសភា ដែលការចំណាយនេះក៏ខ្ពស់ជាងឆ្នាំមុនដែរ។

**ចំណាយរដ្ឋបាល ២០១៨ និង២០១៩**




ប្រភព៖ ការអនុវត្តថវិកា ២០១៨ និង២០១៩

# ព័ត៌មាន និងទិន្នន័យរបស់បណ្តាប្រទេសនៅក្នុងអាស៊ាន និងដៃគូពាណិជ្ជកម្មដទៃទៀត

### អាស៊ានក្លាយជាដៃគូធំទី២របស់ ចិន

ដៃគូពាណិជ្ជកម្មធំជាងគេទីពីររបស់ប្រទេសចិននាពេលនេះ គឺសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ ដែលបានឈានមុខហួសអាមេរិកនៅពាក់កណ្តាលឆ្នាំ២០១៩ នេះបើយោងតាមទិន្នន័យចេញផ្សាយថ្មីៗពីទីភ្នាក់ងារគយរបស់ចិន។

ពាណិជ្ជកម្មរបស់ប្រទេសចិន ជាមួយសមាជិកអាស៊ានបានកើនឡើងជាង៤% ទៅដល់ ២៩២ប៊ីលានដុល្លារ ដែលច្រើនជាងពាណិជ្ជកម្មរវាង អាមេរិក និងចិន ដែលមានចំនួន ២៦០ប៊ីលានដុល្លារ។ ដៃគូពាណិជ្ជកម្មធំបំផុតរបស់ប្រទេសចិននៅតែជាសហភាពអឺរ៉ុប។

ការផ្លាស់ប្តូរស្ថានភាពពាណិជ្ជកម្ម គឺដោយសារតែសង្គ្រាមពន្ធរវាង ចិន និង អាមេរិក ដែលជំរុញឱ្យអាជីវកម្មផ្លាស់ប្តូរផលិតកម្ម និងអ្នកផ្គត់ផ្គង់របស់ខ្លួនទៅកាន់បណ្តាប្រទេសសមាជិកអាស៊ាន។

ការផ្លាស់ប្តូរនេះ អាចមានរយៈពេលខ្លីប៉ុណ្ណោះ នេះបើយោងតាមអ្នកវិភាគធនាគារពិភពលោកប្រចាំប្រទេសថៃ ដែលរំពឹងថា សង្គ្រាមពាណិជ្ជកម្មនឹងផ្លាស់ប្តូរទិសដៅក្នុងរយៈពេលមធ្យម ដែលបន្ថយការរីកចម្រើននៅតំបន់អាស៊ានវិញនៅដើមឆ្នាំក្រោយ។

# សេដ្ឋកិច្ចពិភពលោក

### ផលិតកម្មឧស្សាហកម្ម រក្សាស្ថានភាពមិនផ្លាស់ប្តូរនៅក្នុងខែមិថុនា

ផលិតកម្មឧស្សាហកម្មរបស់ អាមេរិក មិនមានការផ្លាស់ប្តូរទេនៅខែមិថុនា នេះបើយោងតាមស្ថិតិដែលចេញផ្សាយដោយធនាគារកណ្តាល។ ការកើនឡើងនៃវិស័យកម្មន្តសាល និងរ៉ែ ត្រូវបានទូទាត់ដោយការធ្លាក់ចុះនៃក្រុមហ៊ុនក្នុងវិស័យអគ្គិសនី។

កម្មន្តសាលបានកើនឡើង០,៤% ក្នុងនោះរថយន្ត និងគ្រឿងបន្លាស់កើន ៣%។ ទោះជាយ៉ាងណាក៏ដោយ វិស័យផលិតកម្មផ្សេងទៀតកើនឡើងត្រឹមតែ០,២% ប៉ុណ្ណោះ ជាកំណើនដែលបានថយចុះដោយសារតែសង្គ្រាមពាណិជ្ជកម្មរវាងអាមេរិក និងចិន។

វិស័យរ៉ែបានកើនឡើង០,២% ប៉ុន្តែផលិតកម្មអគ្គិសនីរបស់ប្រទេសធ្លាក់ចុះ៣,៦% ដោយសារអាកាសធាតុត្រជាក់ជាងធម្មតា ដែលនាំឲ្យតម្រូវការប្រើប្រាស់ម៉ាស៊ីនត្រជាក់មានការធ្លាក់ចុះ។

## ព័ត៌មានសម្រាប់សប្តាហ៍បន្ទាប់

ទិន្នន័យសម្រាប់សប្តាហ៍ខាងមុខនេះ រួមមានៈ តុល្យភាពថវិកាប្រទេសហ្វីលីពីន អតិផរណា ផលិតកម្មឧស្សាហកម្ម និង និកម្មភាពប្រទេសសឹង្ហបុរី និងអតិផរណាប្រទេសម៉ាឡេស៊ី។

ខាងក្រោមគឺជាប្រតិទិនពេញលេញនៃការចេញនូវទិន្នន័យ និងការអភិវឌ្ឍដែលក្រុម FACT នឹងបន្តតាមដាននៅសប្តាហ៍ក្រោយៈ

ថ្ងៃចន្ទ ទី២២ កក្កដា ២០១៩

- តុល្យភាពពាណិជ្ជកម្មរបស់ថៃ សម្រាប់ខែមិថុនា
- សមតុល្យថវិការបស់ហ្វីលីពីន សម្រាប់ខែមិថុនា
- អត្រានិកម្មភាពរបស់តៃវ៉ាន់ សម្រាប់ខែមិថុនា
- អត្រាអតិផរណារបស់ហុងកុង សម្រាប់ខែមិថុនា

ថ្ងៃអង្គារ ទី២៣ កក្កដា ២០១៩

- អតិផរណារបស់ សឹង្ហបុរី សម្រាប់ខែមិថុនា
- ផលិតផលឧស្សាហកម្មតៃវ៉ាន់ សម្រាប់ខែមិថុនា
- តម្លៃលំនៅឋានរបស់អាមេរិក សម្រាប់ខែឧសភា
- ទំនុកចិត្តអ្នកប្រើប្រាស់នៅតំបន់អឺរ៉ូ សម្រាប់ខែកក្កដា

ថ្ងៃពុធ ទី២៤ កក្កដា ២០១៩

- អតិផរណារបស់ម៉ាឡេស៊ី សម្រាប់ខែមិថុនា
- កំណើនប្រាក់កម្ចីរបស់ឥណ្ឌូនេស៊ី សម្រាប់ខែមិថុនា

ថ្ងៃព្រហស្បតិ៍ ទី ២៥ កក្កដា ២០១៩

- ផ.ស.ស. របស់កូរ៉េខាងត្បូង សម្រាប់ឆ្នាំ ២០១៩
- សមតុល្យពាណិជ្ជកម្មរបស់ហុងកុង សម្រាប់ខែមិថុនា
- ការសម្រេចចិត្តអត្រាការប្រាក់របស់ ECB តំបន់អឺរ៉ូ

ថ្ងៃសុក្រ ទី២៦ កក្កដា ២០១៩

- ទំនុកចិត្តអ្នកប្រើប្រាស់របស់ កូរ៉េខាងត្បូងសម្រាប់ខែកក្កដា
- និកម្មភាពប្រទេសសឹង្ហបុរី សម្រាប់ត្រីមាសទី២ ឆ្នាំ ២០១៩
- ផលិតកម្មឧស្សាហកម្មរបស់សឹង្ហបុរី សម្រាប់ខែមិថុនា
- ការលក់ទោចក្រយានយន្តរបស់ឥណ្ឌូណេស៊ី សម្រាប់ខែមិថុនា
- ការវិនិយោគផ្ទាល់ពីបរទេសរបស់វៀតណាម សម្រាប់ខែកក្កដា